មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៧

# បកិណ្ណកចេតសិក ៦

## ១ - វិតក្កចេតសិក (Initial Application)

អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ = វិតក្កោ ធម៌ណាមួយរមែងត្រិះរិះ (នឹក) ដល់អារម្មណ៍ គឺ លើកសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា វិតក្កៈ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់វិតក្កៈ

១ - អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ

២ - អាហននបរិយាហននរសោ មានការធ្វើចិត្តឲ្យប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច

៣ - អានយបច្ចុប្បដ្ឋានោ មានការនាំចិត្តទៅក្នុងអារម្មណ៍ ជាអាការប្រាកដ

៤ - អាបាថវិសយបទដ្ឋានោ មានអារម្មណ៍ក្នុងវិថី ជាហេតុជិត។

## ២ - វិចារចេតសិក (Sustained Application)

អារម្មណេ តេន ធម្មេន ចិត្តំ វិចរតីតិ = វិចារោ ចិត្តរមែងត្រាច់ទៅក្នុងអារម្មណ៍ ដោយធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា វិចារៈ ។

# លក្ខណាទិចតុក្កៈរបស់វិចារៈ

| | |
|---|---|
| ១ - អារម្មណានុមជ្ជនលក្ខណោ | មានការពិចារណាក្នុងអារម្មណ៍ ជាលក្ខណៈ |
| ២ - តត្ថ សហជាតានុយោជនរសោ | មានការតាមប្រកបសហជាតធម៌ទុកក្នុងអារម្មណ៍ ជាកិច្ច |
| ៣ - ចិត្តានុបពន្ធបច្ចុប្បដ្ឋានោ | មានការចងចិត្តទុកក្នុងអារម្មណ៍ ជាអាការប្រាកដ |
| ៤ - អារម្មណបទដ្ឋានោ | មានអារម្មណ៍ ជាហេតុជិត។ |

# ៣ - អធិមោក្ខចេតសិក (Decision)

អធិមុច្ចនំ = អធិមោក្ខោ ការបង្អោនចិត្តទៅ

(ឬជឿយ៉ាងស៊ប់) ឈ្មោះថា អធិមោក្ខៈ ។

# លក្ខណាទិចតុក្កៈរបស់អធិមោក្ខៈ

| | |
|---|---|
| ១ - សន្និដ្ឋានលក្ខណោ | មានការដាក់ចិត្តស៊ប់ ឬសម្រេច *(សន្និដ្ឋាន)* ជាលក្ខណៈ |
| ២ - អសំសប្បនរសោ | មានការមិនសង្ស័យ *(ឬមិនឃ្លេងឃ្លោង)* ជាកិច្ច |
| ៣ - វិនិច្ឆយបច្ចុប្បដ្ឋានោ | មានការចុះចិត្តស៊ប់ *(ឬកាត់សេចក្តី)* ជាការប្រាកដ |
| ៤ - សន្និដ្ឋេយ្យធម្មបទដ្ឋានោ | មានធម៌ដែលគប្បីសម្រេច *(សន្និដ្ឋាន)* ជាហេតុជិត។ |

** អធិមោក្ខៈនេះ ជាបដិបក្ខនឹងវិចិកិច្ឆា។*

# ៤ - វីរិយចេតសិក (Effort)

វីរានំ ភាវោ កម្មំ វា វិធិនា ឥរយិតព្វំ បវត្តេតព្វន្តិ វា = វីរិយំ

ឧស្សាហោ ភាវៈ ឬការងាររបស់អ្នកអង់អាច ឈ្មោះថា វីរិយៈ។ មួយទៀត ធម្មជាតិណា ដែលបុគ្គលគប្បីឲ្យមានដំណើរទៅ គប្បីឲ្យប្រព្រឹត្តទៅដោយវិធី ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វីរិយៈ បានដល់សេចក្ដីព្យាយាម។

# លក្ខណាទិចតុក្កៈរបស់វីរិយៈ

| | |
|---|---|
| ១ - ឧស្សាហលក្ខណំ | មានការឧស្សាហ៍ ជាលក្ខណៈ |
| ២ - សហជាតានំ ឧបត្ថម្ភនរសំ | មានការឧបត្ថម្ភដល់សហជាតធម៌ ជាកិច្ច |
| ៣ - អសំសីទនភាវបច្ចុប្បដ្ឋានំ | មិនមានការរាថយ ជាអាការប្រាកដ |
| ៤ - សំវេគវត្ថុបទដ្ឋានំ | មានសំវេគវត្ថុ ជាហេតុជិត ។ |

# សំវេគវត្ថុ ៨

ហេតុជាទីតាំងនៃសេចក្តីសង្វេគ ហៅថា សំវេគវត្ថុ មាន ៨ គឺ ៖

- ការពិចារណាដល់ជាតិទុក្ខ ១
- ការពិចារណាដល់ជរាទុក្ខ ១
- ការពិចារណាដល់ព្យាធិទុក្ខ ១
- ការពិចារណាដល់មរណទុក្ខ ១
- ការពិចារណាដល់អបាយិកទុក្ខ ១
- ការពិចារណាដល់អតីតវដ្តមូលកទុក្ខ ១
- ការពិចារណាដល់អនាគតវដ្តមូលកទុក្ខ ១
- និងការពិចារណាដល់ទុក្ខ ក្នុងការស្វែងរកអាហារក្នុងបច្ចុប្បន្ន ១។